**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៤៦)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ២ ៣២៨ នាក់ នៃរោងចក្រ សហគ្រាស ទាំង២៧ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ០០០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២០ ០០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦០ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង២៧ នេះ មិនបានទទួលសារទូរសព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ អង្គារ ១៤កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២១

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍**
**ចំនួន ២៧ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 5 |
| 1 | ក្រុមហ៊ុន ដាប់ប៊ីលយូ អ៊ែនដ៏ ឌី កម្ពុជា | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ហាណា (ខេមបូឌា) អ៊ីង | ភ្នំពេញ |
| 3 | ក្រុមហ៊ុន យីង ហ្វេសិន ហ្គាមេន | ភ្នំពេញ |
| 4 | ក្រុមហ៊ុន វ៉ាន់កូ អ៊ិនដាសស្ទ្រៀល ខូ អិលធីឌី | កណ្តាល |
| 5 | ក្រុមហ៊ុន អ៊ី ហ្គាមេន ខូអិលធីឌី | កណ្តាល |
| ខ. វិស័យទេសចរណ៍ | | 22 |
| 6 | ក្រុមហ៊ុន បាអាតហ្គត | ភ្នំពេញ |
| 7 | ក្រុមហ៊ុន អលមិន ខូ អិលធីឌី | ភ្នំពេញ |
| 8 | ក្រុមហ៊ុន អិល&អិម បាសាក់ រីវើរ ខូ អិលធីឌី | ភ្នំពេញ |
| 9 | ក្រុមហ៊ុន វើលដ៍ ដាយនីង លីមីធីត | ភ្នំពេញ |
| 10 | សណ្ឋាគារ រ៉ាហ្វិល រ៉ូយ៉ាល់ | ភ្នំពេញ |
| 11 | សណ្ឋាគារ រ៉េស៊ីដង់ សុខាភ្នំពេញ | ភ្នំពេញ |
| 12 | ក្រុមហ៊ុន ដារ៉ា អ៊ែរផត ហូថេល | ភ្នំពេញ |
| 13 | ក្រុមហ៊ុន វីណា ហុងកុង ខំផែនី អែលធីឌី | ភ្នំពេញ |
| 14 | ក្រុមហ៊ុន អេស៊ា អិចផ្លរើ ត្រាវែល | ភ្នំពេញ |
| 15 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |
| 16 | ក្រុមហ៊ុន គូបេ យែភែននីស វែស្ទូវែន | សៀមរាប |
| 17 | ក្រុមហ៊ុន ផ្លាហ្សា ព្រីមៀ ឡូញ (ខេមបូឌា) សាខាសៀមរាប | សៀមរាប |

| ល.រ | ឈ្មោះភោជនីយដ្ឋាន សណ្ឋាគារ | រាជធានី ខេត្ត |
|---|---|---|
| 18 | ភោជនីយដ្ឋាន វិរតន៍ | សៀមរាប |
| 19 | សណ្ឋាគារ វិរតន៍ | សៀមរាប |
| 20 | ក្រុមហ៊ុន វិរតន៍ វីឡា | សៀមរាប |
| 21 | ក្រុមហ៊ុន រ៉ូយ៉ាល់អង្គរ (សណ្ឋាគារសូហ្វីតែលអង្គរភូគីត្រាហ្គោហ្វ & ស្ប៉ារីហ្សត) | សៀមរាប |
| 22 | សណ្ឋាគារ តារា អង្គរ | សៀមរាប |
| 23 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 24 | ក្រុមហ៊ុន អេមព្រីស អង្គរ | សៀមរាប |
| 25 | សណ្ឋាគារខេមរាអង្គរ | សៀមរាប |
| 26 | ក្រុមហ៊ុន ដឹ សុទ្ធា (ខេ.វី) ភីធីអ៊ី អិលធីឌី | សៀមរាប |
| 27 | ក្រុមហ៊ុន ម៉េម៉រ អង្គរ | សៀមរាប |